ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

**ឯកឧត្តម ប្រាក់ សុខុន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូអញ្ជើញទៅចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ ដូចខាងក្រោម ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី ០៥ ដល់ថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០១៧ នៅទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន តាមការអញ្ជើញរបស់ **ឯកឧត្តម អាឡាន ភីទ័រ កាយ៉េតាណូ** រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋហ្វីលីពីន។

- កិច្ចប្រជុំគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ
- ជំនួបរវាងរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយតំណាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស
- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥០
- សន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស
- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូកបីលើកទី១៨
- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចប្រជុំកំពូលអាស៊ី-បូព៌ាលើកទី៧
- វេទិកាតំបន់អាស៊ានលើកទី២៤ និង
- ពិធីអបអរសាទរទិវាអាស៊ាន ខួបលើកទី៥០ ។

ក្នុងនាមជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សាធារណរដ្ឋកូរ៉េ **ឯកឧត្តម ទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** នឹងធ្វើជាសហប្រធានកិច្ចប្រជុំ "សន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសបូកសាធារណរដ្ឋកូរ៉េ" ជាមួយ លោកជំទាវ **កាង យ៉ុងវ៉ា** រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ។

ក្រោមមូលបទ "រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្តូរ រួមចំណែកជាមួយពិភពលោក" កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥០ និងកិច្ចប្រជុំពាក់ព័ន្ធ នឹងផ្តោតជាសំខាន់លើការកំណត់របៀបវារៈអាស៊ានក្នុងឋានៈជាតួអង្គសំខាន់មួយក្នុងសាកលលោក បន្ទាប់ពី៥ទសវត្សរ៍នៃការចាប់បដិសន្ធិ។ ស្របជាមួយគ្នានេះ ដោយពិចារណាលើផ្នែកស្ថានភាពភូមិសាស្ត្រនយោបាយ និងដំណើរវិវត្តនៃ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

និម្មាបនកម្មតំបន់ អាស៊ានបានក្លាយខ្លួនទៅជាតំបន់ដែលមានការប្រកួតប្រជែងមួយ ក្នុងចំណោមប្រទេសមហាអំណាចសំខាន់ៗ លើផ្នែកសន្តិសុខ និងសេដ្ឋកិច្ច។

ក្រៅពីការអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** នឹងចូលរួមកិច្ចប្រជុំដទៃទៀត ដូចខាងក្រោមៈ

- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសគំនិតផ្តួចផ្តើមមេគង្គក្រោម លើកទី១០
- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុន លើកទី១០ និង
- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស នៃកិច្ចសហប្រតិបត្តិការមេគង្គ- គង្គា លើកទី១០។

ក្នុងអំឡុងពេលស្នាក់នៅប្រទេសហ្វីលីពីន **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** រួមជាមួយរដ្ឋមន្ត្រីការបរទេសអាស៊ានដទៃទៀត នឹងជួបសំដែងការគួរសមជាមួយឯកឧត្តម **រ៉ូឌ្រីហ្គោ ឌូតឺតេ** ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន។

បន្ថែមពីនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** នឹងជួបពិភាក្សាទ្វេភាគីផងដែរជាមួយរដ្ឋមន្ត្រីការបរទេស និងប្រមុខគណៈប្រតិភូនៃប្រទេសមួយចំនួន។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៧